បន្ទាប់មកមេឃខ្មៅមីរ រកភ្លៀង ។ សម្លេងក្តុងៗពីចម្ងាយ ។

-បង! សម្លេងផ្គរឬ?

-មិនមែនទេ!មាសបង

-នេះជា សម្រែកសង្គ្រាម ! សម្លេងកាណុងបាញ់ផ្ទោង បំផ្លាញក្រុង បំផ្លាញជីវិតមនុស្សនានា។ ទិសដៅរបស់គេ គឺសំដៅទៅយកអំណាច នៅក្រុងភ្នំពេញ ។ តែមុននឹងទៅដល់ភ្នំពេញ គេត្រូវកំទេចឲ្យអស់ជននានា រួចភូមិស្រុក រួចខេត្តនានា ។ កំទេចឲ្យអស់ផ្ទះអ្នកក្រ ដុតភូមិឋាន ភូមិគ្រឹះ ព្រោះតែចង់បានអំណាច ។ នៅស្រុកគេ ក៏ដូច្នោះដែរ កាលពីជំនាន់ដើម ។ តែដល់ឥឡូវ ដើម្បី ចៀសវាងកុំឲ្យមានសង្គ្រាម បំផ្លាញទ្រព្យសម្បត្តិ អ្នកស្រុក ដែលគ្មានទាក់ទាមរឿងនេះ គេបង្កើតឲ្យមានការបោះឆ្នោតឡើង ។

អូនសម្លាញ់បងអើយ! សង្គ្រាមនៅមិនឆ្ងាយ ពីអង្គរទេ ។ សង្គ្រាម នឹងរាលដាល មកដល់អង្គរ ថ្ងៃណាមួយ មិនខាន ។ ដីខ្មែរនឹងប្រឡាក់ ដោយឈាមខ្មែរ ។ ដីខ្មែរនឹងស្រោចស្រព ដោយទឹកភ្នែករាស្ត្រប្រជា វេទនារកទីបំផុតគ្មាន ។

កូនរំសេវ កូនឈាម ទាមទារ ទាញវាសនាខ្មែរ ឲ្យរអិល បន្តិចម្តងៗ ធ្លាក់ក្នុងរណ្តៅអវចី ដុតសាសន៍ឯង បំផ្លាញផ្ទះសម្បែងឲ្យខ្ទេចជាផេះ ។

គ្មានអ៊ីឃាត់ឃាំងបានឡើយ ព្រោះយើង គ្មានផ្លូវណាឲ្យប្រសើរ ជាជាងសម្លាប់គ្នា ដើម្បីអំណាច ។ នេះជាកម្មយើងទាំងអស់គ្នា?

នៅស្រុកគេ ដើម្បីចៀសវាង កាប់សម្លាប់គ្នា គេធ្វើការបោះឆ្នោត រើសយកអ្នកខ្លាំងពូកែ អ្នកដែលមានសមត្ថភាពជាងគេ ដោះដូរផ្លាស់គ្នា ទៅតាមកាលៈទេសៈ ។

ការដែល ដណ្តើមអំណាច ដោយ កម្លាំង បាយ កម្លាំងអាវុធ ពុំអាចឲ្យគេកាន់អំណាច យូរបានឡើយ ។ ហើយដល់ពេលធ្លាក់ ត្រូវក្សិណក្ស័យ របស់ទ្រព្យត្រូវគេរឹបយក ប្រពន្ធកូនត្រូវគេធ្វើបាប... ឈាមសងឈាម គំនុំសងគំនុំ ។

បងអើយ! អូនភ័យព្រួយ ភ័យខ្លាច និងរងា កំព្រាចិត្តពន់ពេក ។

ទឹកភ្នែកឆេទី ហូរធ្លាក់ លើថ្ពាល់ដ៏ផូរផង់ ។

តើអូនមានរឿងអ្វី ធ្ងន់ក្នុងចិត្ត បានជាទឹកភ្នែក ស្រក់ហូរច្រើនម្ល៉េះ?

បងអើយ! អតីតកាល ណែនណាន់ តាន់តាប់ នៅក្នុងបេះដូងអូនៗ អូនចង់និទានរឿងអូនឲ្យបងស្ដាប់ មិនចាំបាច់បងដណ្ដឹងសួរទាន់ឡើយ។ តែរាល់ដង យើងខ្វះឱកាសល្អ ។ ណាមួយ អូនអៀនខ្មាស ហាក់ដូចជាហែកទ្រូងឯង ។ តែអូនចង់ឲ្យ បងស្គាល់ច្បាស់ នូវរឿងរ៉ាវ របស់អូន ចង់ឲ្យ បងស្គាល់ច្បាស់ពីអូន មុននឹងសំរេចចិត្ត កុំឲ្យស្ដាយក្រោយ ។ ការខ្វះខាតរមែងតែមាន តែយើងជួយបង្រួបគ្នា កាន់ដៃគ្នាទៅរកអនាគតភ្លឺស្វាង។ អូនមិនមែនជាកូនគហបតី របស់អ្វីមានប្រើមិនខ្វះនោះទេ ។ អូនមិនមែនជាអ្នកផិតផាយ សប្បាយរាល់រាត្រីសប្បាយនឹងពន្លឺពេជ្រនឹងពន្លឺអគ្គិសនី ។ អូនធ្វើការហត់នឿយណាស់បងអើយ!



អូនស្គាល់ថ្លៃប្រាក់រៀល ទំរាំបានមួយរៀលៗ ត្រូវប្រឹងប្រែង ប្រឹងញញឹមទទួលភ្ញៀវ ពីព្រលឹមទល់ព្រលប់ ។ ញញឹមរហូត ដល់អ្នកខ្លះថា អូនប្រហែលជា មិនដែលកើតទុក្ខទេឬ?

ខេមរា ផ្ទេកក្បាលលើស្មាឆេទី រួចបិទភ្នែក គ្មានគិតអ្វីទាំងអស់ ។ នាយបឺតដកស្រូបក្លិនសក់ស្រស់ស្រី ក្រអូបឈួលហឫទ័យ សាច់សល្អខ្ចី គួរឲ្យបេតិ ហួសប្រមាណ ។ ខ្យល់ត្រសៀកបក់សក់ស្រស់ស្រី ក្រោមលើភក្រ្តា ខេមរា ។

នេះហើយ ដែលគេហៅថា សុភមង្គល។ គ្មានឋានសួគ៌ឯណាទៀតទេ ។

សង្គ្រាម ហាក់ដូចជានៅឆ្ងាយ ។ យើងភ្លេចនូវទុក្ខសោកទាំងពួង ។

# ជន្លល់រលំ ជីវិតរលាយ

ទឹកភ្នែករហាម លើថ្ពាល់ស្រស់បំព្រង ឆេរី ខំប្រមូលកម្លាំងស្មារតី និទានរឿងរបស់ខ្លួន ។

ពុកខ្ញុំធ្វើជាទាហាន ក្នុងកងទ័ពខេមរភូមិន្ទ មានពាក់សញ្ញា រូបហនុមាន បានសេចក្ដីថា ក្លាហាន ចិត្តស្មោះចំពោះជាតិ សាសនា ព្រះមហាក្សត្រ ។

នៅផ្ទះខ្ញុំ មានព្រះពុទ្ធរូប កន្សែងយន្ត ខ្សែបង្កេះ បង្កូមខ្លា ខ្នាយគាន់ ប្រទាលផ្សេងៗ ជួយថែរក្សា ការពារជីវិត ការពារសត្រូវ គ្រប់ប្រភេទ កុំឲ្យមកបៀតបៀនបានឡើយ ។

រាល់ថ្ងៃសីល ពុកតែងស្លៀកស ពាក់ស អង្គុយបត់ជើង សូត្រធម៌ ។ ជាកិរិយា ផ្ទុកពីទាហានជំនាន់នោះ ដែលខុះឱបដបស្រា និងស្រីបារ ។

ពុកបានរួមធ្វើចំបាំងជាច្រើន តាំងពីទាមទារឯករាជ្យ រហូតបានជោគជ័យ ពីបារាំង ។ រួចមក ពេលដែលបានឯករាជ្យហើយ យួនពុំព្រមដកទ័ពចេញពីក្រចេះ ស្ទឹងត្រែង ស្រែជេស ។ល។

ពុកថ្លែង ព្រះមហាក្សត្រធ្វើបូជនីយកិច្ចដេញយួន អស់ពីទឹកដីយើង ។ អស់ពីយួន សៀមចូលមកយកព្រះវិហារទៀត ។ ពុកត្រៀមចាំ តទល់ទ័ពសៀមទៀត ការពារទឹកដីខ្មែរ ។ រាល់ដងពុក អង់អាចក្លាហាន ទាញកន្សែងយន្តរុំក លោតលើឡានហ្ស៊ីប សំដៅសមរភូមិ ។ ភ័ក្ត្រញញឹមសង្ឃឹមលើជ័យជំនះ គ្រវីដៃលា ម៉ែ និងកូនទៅការពារមាតុភូមិ ។

លើខ្លួនពុក មានសន្លាកស្នាមរបួស ។ សន្លាក និមួយៗ ជារឿងសង្គ្រាមរវាងខ្មែរនិងប្រទេសជិតខាង ។

រាល់ដង ដែលពុកទៅច្បាំង ខ្ញុំ និង ម៉ែ និង ប្អូន រស់នៅដោយក្រៀមក្រំ ។ លែងសើច លែងក្អាកក្អាយ ដូចពេលមុនទៀតហើយ ។

រង់ចាំ! រង់ចាំពុកមកវិញ!

បាត់ដំណឹងយូរ! ខ្ញុំយករូបថត ពុកមកដេកឱប ។ ពុក ស្រឡាញ់លុយ? ស្រឡាញ់គ្រួសារ ឬស្រឡាញ់ជាតិ?

ថ្ងៃមួយ មុនរដ្ឋប្រហារបន្តិច ពុកបាននិយាយទៅកាន់ម៉ែថា៖

ខ្ញុំអាចច្បាំងនឹងខ្មាំងបរទេស ការពារទឹកដីខ្មែរបាន តែឲ្យខ្ញុំសម្លាប់ខ្មែរ ខ្ញុំធ្វើមិនរួចឡើយ ។ ណាមួយ ខ្ញុំបានផឹកទឹកសម្បថទៀតផង ។ ប្រហែលជាពុកមានលេចឮថា ទាហានប្រុងក្បត់យកអំណាចក៏មិនដឹង ។

តែពុកឥតមាននិយាយអ្វីឲ្យហួសពីនេះទៀតឡើយ ។

ខេមរា បន្ទែម! អ្នកដែលផឹកទឹកសម្បថហើយក្បត់ អ្នកនោះប្រព្រឹត្តនូវកំហុសត្រួតគ្នា ។

ថ្ងៃមួយ ពុកទឹកមុខស្រងូត ខុសពីធម្មតា ។ ពុកទាញកាំភ្លើងខ្លីមកសៀតចង្កេះ រួចឱបលាម៉ែជាចុងក្រោយ ។ ប្អូនខ្ញុំផ្សេងទៀត ឱបជើងឪពុក ដោយគ្នានៅក្មេងពេក ខ្លះផ្ដាំឲ្យខ្ញុំទិញនំផ្ញើវាផង ។

ពុក លើកកូនឱបនឹងដងទ្រូង ម្ដងមួយៗ សួរសំណេះសំណាល ពីនេះពីនោះ ។

ពុកឱបខ្ញុំ រួចផ្ដាំថា ចូរកូនជួយមើលប្អូនតូចៗផង ជីវិតជាការតស៊ូ មិនស្រួលដូចយើងនឹកស្មាននោះទេ ។ តម្លៃរបស់យើង ជាពន្លឺរបស់យើង ។ ពឹងផ្អែកលើគេ មិនអាចឋិតថេរបានយូរឡើយ ។

ជាលើកដំបូងហើយ ដែលខ្ញុំឃើញពុកស្រក់ទឹកភ្នែក ពេលចេញទៅច្បាំង ។

ខ្ញុំតាមមើលឡានហ្ស៊ីប ដែលដឹកពុក ចេញទៅរហូតផុតកន្ទុយភ្នែក ។

ខ្ញុំបាត់ដំណឹង ពុកតាំងពីពេលនោះមក ។

ក្រោយមក រូបថតពុក ត្រូវម្ដាយខ្ញុំយកទៅដាក់ជិតព្រះពុទ្ធរូប ហើយគាត់អុជធូបបូជា រាល់ថ្ងៃសីល ។

កូនមួយនៅក្នុងពោះម៉ាក់ ម៉ាក់ឲ្យគេយកចេញ ព្រោះពីថ្ងៃនេះទៅ យើងរស់នៅពុំដូចពេលមុនឡើយ ។ ជីវិតយើងនឹងជួបនូវគ្រោះភ័យ ដូចបងប្អូនខ្មែរឯទៀត ។

ក្រោយពីពុកបាត់ខ្លួនមក ម្ដាយខ្ញុំចាប់ឈឺខ្សិន ធ្វើការពុំរួច ។

ឱទីនាងយំ! ខ្ញុំធំជាងគេ ខំប្រឹងជ្រោលទូលគ្រួសារ ។ បងអើយ! ខ្លួននៅក្មេងពេក ពុំសូវយល់ការរស់នៅ ពុំដឹងបញ្ហាគ្រួសារ ពុំដឹងភារៈឪពុកម្ដាយ ។ គ្រួសារខ្ញុំរលំ ។ បងប្អូនបែកខ្ញែកគ្នា ទៅរស់នៅផ្ទះមីងមា ។ គេជួយយករក្សាចិញ្ចឹម ។

ឱទីបន្ត! បងអើយ! អូនអភ័ព្វណាស់ ។ សង្គ្រាមទាមទារ ឈាមគ្រួសារអូន បន្ទាប់ពីឪពុក ឥឡូវឪពុកមាទៀតហើយ ។ ប្ដីមីងខ្ញុំបាត់ខ្លួននៅសមរភូមិ ឧត្ដរមានជ័យក្នុងពេលថ្មីៗនេះ ។

មីងតែលតោល ឥតមានកម្លាំងកំហែង នឹងប្រឹងរកស៊ីតទៅទៀតទេ ។ គាត់បាន លក់ភោជនីយដ្ឋានទៅឲ្យគេហើយ ។

ជីវិតខ្ញុំ មិនដឹងជាយ៉ាងណាទេ?

ឱសង្គ្រាម! អ្នកបឺតស្រូបឈាមខ្មែរ ។ អ្នកផ្ដាច់ព្រលឹងជីវិតមនុស្សដែលខ្ញុំស្រឡាញ់ ។ អ្នកសាហាវណាស់! អ្នកគ្មានធម៌មេត្តា! មិនគ្រាន់តែផ្ដាច់ជីវិតមនុស្ស ដូចយមបាល អ្នកបំផ្លាញផ្ទះសម្បែង បំផ្លាញភូមិដ្ឋានរបស់របរ ឲ្យមនុស្សធ្លាក់ខ្លួនបុះក្រ ឲ្យប្រទេសហិនហោច ខ្លោចផ្សាវេទនា ។

តើត្រូវតែធ្វើសង្គ្រាម ចៀសមិនរួច? គ្មានមធ្យោបាយណា ក្រៅពីសម្លាប់ ស៊ីសាច់ហុតឈាមគ្នា? សង្គ្រាមមិនឆ្អែតឆ្អន់ តើអ្នកណាបានចំណេញច្រើនជាងគេ ពេលមានសង្គ្រាមម្ដងៗ? ខ្មែរជឿព្រះពុទ្ធសាសនា ពុំហ៊ានសម្លាប់សត្វទេ តែខ្មែរសម្លាប់គ្នាឯង ស្លាប់ច្រើនជាងបរទេសសម្លាប់ទៅទៀត ។

នៅឯនាយជើងមេឃឆ្ងាយ ស្នូរកាំភ្លើង ពុសន្ធាប់ ។ ខ្មែរថ្លែងសរសម្លាប់ខ្មែរ ។ ក្នុងមួយជំនាន់ៗ ខ្មែរស្គាល់តែទឹកភ្នែក ព្រាត់ប្រាសគ្នា ។ ម្ដងនេះ មិនដូចពេលមុនខ្មែរនិងសៀមនោះទេ តែខ្មែរនិងខ្មែរ ។

# សង្គ្រាម
# រវាងខ្មែរនិងសៀម

៙៙៙

ឆេរី សួរ! ហេតុដូចម្ដេចបានជាខ្មែរចុះចាញ់ បន្ទាប់ពីអង្គរមក?

ខេមរា- មិនមែនមកពីអង្គរទេ ។ ខុះថាខ្មែរបាក់កម្លាំងមកពីសង់អង្គរ? តើប្រទេសបារាំង មានសង់អង្គរទេ បានជាបាត់រូបពីលើផែនទី?

នាជំនាន់ដើម ប្រទេសដែលអាច យកជ័យជំនះ លើសត្រូវបាន ត្រូវប្រកបនូវកត្តាបីយ៉ាង៖

-ព្រះអាទិទេពឲ្យឈ្នះទើបឈ្នះបាន

-គុណសម្បត្តិនិងគុណធម្មនៃមេទ័ព

-ប្រជាជនគាំទ្រ

ព្រះបាទត្រសក់ផ្អែមនិងក្សត្រតៗមក ខុះនូវវិជ្ជាមេទ័ព មិនមែន ជាមេទ័ព និងមិនមែន ជាអាទិទេព មកចាប់បដិសន្ធិ ធ្វើឲ្យខ្មែរ ខុះនូវជំនឿ លើមេរបស់ខ្លួន ។

ខេមរា បន្ត!

ស្ដេចសៀមនិមួយៗ សុទ្ធតែជាព្រះអាទិទេព មកចាប់បដិសន្ធិ ។

-ស្ដេចត្រៃលោក៖ អាទិទេព ១១ អង្គ មកចាប់បដិសន្ធិ កើតជាត្រៃលោក មួយអង្គឯង៖ ព្រះព្រហ្ម ព្រះនារាយណ៍ ព្រះវិស្ណុ ព្រះឥន្ទ្រ ព្រះពិរុណ ព្រះវាយោ ព្រះអគ្គិ ព្រះអាទិត្យ និងព្រះចន្ទ្រ ។

ព្រះឥន្ទ្រធិរាជា (១៣៧០-១៣៨៧) ព្រះឥន្ទ្រ មកចាប់បដិសន្ធិ ។

ព្រះរាមាសាន់ (១៣៨៨-១៣៩៥) ព្រះរាម មកចាប់បដិសន្ធិ ។

ប្រទេសសៀមពីដើម ឈ្មោះថាណងចៅ ។ នៅឆ្នាំ ១២៥៣ ទ័ពម៉ុងហ្គោល វាតត្បាតប្រទេសចិន និងរាជា

ណាចក្រណាងចៅ ដេញជំរុញសៀម ឲ្យរត់ចុះមកខាងត្បូង (ខាងប្រទេសខ្មែរ) ។ កាលណោះយុទ្ធសាស្ត្រម៉ុងហ្គោល មានប្រសិទ្ធិភាពណាស់ ច្បាំងឈ្នះប្រទេសនានា វាយផ្ទាយរហូតដល់អឺរ៉ុប ដោយប្រើទ័ពសេះយ៉ាងលឿនរហ័ស ។

ទ័ពសៀម ដែលធ្លាប់ប៉ះទង្គិចនឹងទ័ពម៉ុងហ្គោល មានការពិសោធន៍ និងស្គាល់នូវយុទ្ធសាស្ត្រថ្មីៗ របៀបប្រើសេះក្នុងសង្គ្រាម ។

ខ្មែរនៅប្រើយុទ្ធសាស្ត្រ តាមរបៀបឥណ្ឌៀ ប្រើកងថ្មើរជើងច្រើន និងដំរីជាជំនួយ ។

របៀបរៀបទ័ព រៀបក្បួនព្យុហយាត្រា ប្រើពលច្រើន ។ ឯដំរីទៀត មានគុណវិបត្តិខ្លាំង ដោយដំរីខ្លាចភ្លើង។ ពេលឃើញភ្លើង ដំរីបត់ក្បាលរត់ជាន់ទ័ពខ្លួនឯង ។ ហេតុដូចនេះហើយ បានជាយើងឃើញនៅអឺរ៉ុប ពុំមានប្រើដំរី ក្នុងសង្គ្រាមឡើយ ។ គេបានដឹកនាំដំរី យកមកពិសោធ តែពុំមានប្រសិទ្ធិភាព ។

ទ័ពសេះលឿនជាងដំរី បាញ់ព្រាវៗ រួចជិះផាយយ៉ាងលឿន គេចបាត់ ។

មិនតែប៉ុណ្ណោះ សៀមមានគំរោងយូរអង្វែង ផែនការវាយយកស្រុកខ្មែរ ។ គេកសាងក្រុងនីមួយៗ សមស្របទៅតាមផែនការសង្គ្រាប ។ ពីទីក្រុងមួយ ទៅក្រុងមួយទៀត មិនត្រូវមាន ចម្ងាយលើពី ២ ថ្ងៃ បើគេធ្វើដំណើរតាមជើង ។ នេះសំរាប់ឲ្យកងទ័ពបានសំរាក មុននឹងធ្វើដំណើរ តទៅមុខទៀត ។

មិនតែប៉ុណ្ណោះ សៀមប្រើល្បិច បំបាក់ស្មារតីខ្មែរ ឲ្យជឿថា អង្គរជាគ្រោលគោព្រះឥន្ទ្រ ។ ដោយស្តេចសៀម ព្រះឥន្ទ្រធិរាជ ជាព្រះឥន្ទ្រមកចាប់កំណើត ឯខ្មែរជាអ្នកចាំចំការត្រសក់ ខុសគ្នាមេឃនិងដី ។ ធ្វើម្តេចឡើយ នឹងលើកកាំបិត តតាំងច្បាំងនិងព្រះឥន្ទ្រឈ្នះ ។ បាញ់នោះ ហៅមិនឮ !

ព្រះបាទត្រសក់ផ្អែម អ្នកចាំចំការត្រសក់ និងយាមគ្រោលគោឲ្យស្តេចសៀម នេះបើបង្រួមសេចក្តីមក ។

ខេមរា បន្ត!

នៅឆ្នាំ១២៨២ ស្តេចសៀមឈ្មោះ រាមាកំហែង បាន ទៅចងមិត្តភាពជាមួយស្តេចចិន ។

រួចមក រាមា កំហែង បានជួបជាមួយ ព្រះមហា ខាន់គូប៊ីឡៃ (ស្តេចម៉ុងហ្គោល) នាឆ្នាំ១២៩៤ ហើយឆ្នាំ១៣០០ រាមាកំហែង បានវិលទៅម្តងទៀត ទៅជួបអធិរាជប្រទេសចិន ។

នៅឆ្នាំ១២៣៨ មេទ័ពសៀម២នាក់ (ប្រាបួង និងបងឃ្លាំងតៅ) ចុះសន្ធិសញ្ញា ជាបក្សសម្ព័ន្ធនឹងគ្នា ដេញខ្មែរចេញពីសុខោទ័យ ។

ក្រោយមកបងឃ្លាំងតៅ ឡើងសោយរាជ ដោយយកឈ្មោះជាព្រះបាទស្រីឥន្ទ្រាទិត្យ ហើយចាប់ដេញខ្មែរ និងមនចេញពីដីសៀម ។

នៅឆ្នាំ១២៨៧ ស្តេចសៀម បីអង្គ ចុះសន្ធិសញ្ញា ជាបក្សសម្ព័ន្ធនឹងគ្នា ៖

-រាមាកំហែង ស្តេចសុខោទ័យ ជាកូនឃ្លាំងតៅ

-ម៉ាងរ៉ៃ ស្តេចនៅឈៀងរ៉ៃ

-ង៉ាំមួង ស្តេចនៅផាយ៉ៅ

ព្រះបាទរាមាកំហែង បានរើខ្លួនពីក្រោមការត្រួតត្រានៃប្រទេសខ្មែរ ។

យើងឃើញហើយ រាមាកំហែង បានធ្វើដំណើរ ទៅប្រទេសចិន ទៅជួបព្រះខាន់គូប៊ីឡៃ ទៅរៀន ទៅមើលរបៀបរបបស្រុកគេ ។

ការបេះដូងទាំងនេះ ជាកត្តាមួយធ្វើឲ្យប្រទេសសៀមមានប្រៀបមកលើប្រទេសខ្មែរ ។

ម្ចាស់ថ្លៃ! អង្គុយស្តាប់ ការបរិយាយរបស់ឆេទី រួចបន្ថែមថា៖

ពេលដែលលោកជូវតាក្វាន់បេសកទូតចិនធ្វើទស្សនកិច្ចនៅប្រទេសខ្មែរ នាឆ្នាំ១២៩៦ លោកបានឃើញ ប្រទេសខ្មែរ ខ្ទេចខ្ទាំ ដោយមានសង្គ្រាម ជាមួយថៃ រួចមកម្តងហើយ ។

ចាប់ពីឆ្នាំ១៣៥២ រាមាធិបតី បានឲ្យកងទ័ពសៀម លុកលុយប្រទេសខ្មែរ ឡោមព័ទ្ធ រាជធានីអង្គរ ហើយដណ្ដើមយកបាន នៅឆ្នាំ១៣៥៣ ។ សៀមប្លន់យកអស់របស់មានដំឡៃផ្សេងៗ តាំងពីរបាំព្រះរាជទ្រព្យ ឡើងទៅ ។

សៀមដាក់ព្រះអង្គម្ចាស់សៀម មួយអង្គ ឲ្យត្រួតត្រាខ្មែរ រហូតដល់ឆ្នាំ១៣៥៧ ទើបខ្មែររើខ្លួនរួច ។

រាល់ដង ដែលសៀមដកទ័ពថយទៅ សៀមដុតបំផ្លាញអង្គរអស់ ។

ដល់ឆ្នាំ១៤៣១ សៀមវាយលុកលុយចូលស្រុកខ្មែរម្ដងទៀត ដុតកំទេចអង្គរ កាត់មែក កាត់ធាង កាត់ឫស គាស់រំលើងឫស រុញផ្ដួល មហារុក្ខាខ្មែរ ឲ្យដួលផ្ងារ ហារមាត់លែងរួច ។

ខ្មែរសំរេចបោះបង់អង្គរចោល ។ ខ្មែរចុះខ្សោយជាលំដាប់តរៀង រហូតមក ។

ប្រុទ្ធស័ះបន្ត!

ស្ដេចសៀម ដែលវាយយកអង្គរ ជំនាន់នោះមានឈ្មោះដូចតទៅ៖

ឆ្នាំ១៣៦៩-ស្ដេច អ៊ូថុង -ព្រះវិស្ណុ មកចាប់កំណើត ;

ឆ្នាំ១៣៨៨-៨៩ - ស្ដេចរាហ សាន់ —ព្រះរាម ចាប់ កំណើត

ឆ្នាំ១៤៣១-ស្ដេចបរមរាជាទី២

មកដល់ត្រឹមនេះឮសម្លេងកណ្ដឹងរោទ៍ឡើងៗ ឆេរីនាងស្ទុះទៅបើកទ្វារ ឃើញឡុងនិងមិត្តភ័ក្តិជាច្រើនមកលេងៗ

ឡុងជាបងជីដូនមួយឆេរី ។ ឡុងធ្វើការនៅប្រទេសខ្មែរមួយរយៈ ទើបបានអាហារូបករណ៍ មករៀននៅស្រុកបារាំង រហូតដល់បានសញ្ញាប័ត្រ ជាបណ្ឌិតខាងច្បាប់ ។ នៅស្រុកបារាំង មានវិជ្ជាខ្លះ ពិបាករកការងារ ធ្វើណាស់ ព្រោះបារាំង គេឥតត្រូវការ យើងទេ ។

ជំរាបសួរ ប្រុទ្ធស័ះ! ជំរាបសួរ ឆេរី! ឡុងនិយាយ ។

-ប្រុទ្ធស័ះ បានជាស្រួលបួល ហើយឬនៅ?

- អរគុណច្រើន ខ្ញុំបានស្រួលខ្លះហើយ តែដោយជរាផង សុខភាព ក៏កាន់តែដាបទៅ ។

ប្រូច់សំរ! កុំតែរបួសតុំងាយបាកបោលអង្គរ ឡើយ នេរី និយាយ!

ឡុខសួរ! ចុះ ប្រូច់សំរ មក អ្នកណា ទៅនៅជំនួស ទទួល ថែរក្សាអង្គរ។

ប្រូច់សំរ ដកដង្ហើមធំ រួចពោលថា ពិបាកណាស់ មនុស្ស ល្ងង់ខ្លៅ បង់ដឹកនាំស្រុក ។ ថែតែរបស់ដែលមានរួចហើយ ថែមិនកើតផង រួចអួតខ្លួនថា "មហាលោតផ្លោះ" មហា អស្ចារ្យ ។

អ្នកដែលចង់ជួយ មិនដឹងជាជួយដូចម្ដេច បើខ្លួនចេះ អស់ ហើយ ខ្លួនគ្រាន់បើហើយ ។

នេរី និយាយ! ពេលដែលប្រូច់សំរ មានគ្រោះថ្នាក់ បង ខេមរា ទទួលមើលកិច្ចការជំនួស ។

ខេមរា ជាកូនបញ្ចឹម ប្រូច់សំរ គាត់ស្រឡាញ់ដូចកូនបង្កើត អញ្ចឹង ។ បងខេមរាជាអ្នកស្រឡាញ់អង្គរ មួយដែរ គាត់អង្គុយ ច្នាក់ថ្ម ដែលបាក់បែកឲ្យល្អដូចដើម ។ សម្ដី ក៏ពិរោះ ចិត្ត ទូលាយ អត់ធ្មត់ និងកំដៅថ្ងៃ ឬភ្លៀងផ្គរ ឈរ រំពឹងគិត



ធ្វើយ៉ាងណា ឲ្យអង្គរ រស់ឡើងវិញ ។ តែអង្គរ ត្រូវខ្មែរ សម្លាប់ បោះបង់បោលម្ដងទៀត ។ អង្គរ ជាកន្លែងប្រមូល ផ្ដុំនៃអ្នកចំណានៗ ក្នុងរាជាណាចក្រ ពូតដៃគ្នា កសាង សមិទ្ធិ ជំស្ថិតស្ថេរ ។ នេះហើយ ដែលគេហៅថា មហាលោត ផ្លោះ មហាអស្ចារ្យ ។

ប្រូច់សំរ! ខ្ញុំពុំដែលមានឱកាសនិទាន រឿងខេមរាឲ្យអ្នក ស្ដាប់ទេ តែពេលនេះឱកាសល្អ ខ្ញុំនឹងនិទានរឿងខ្ញុំ និង រឿង ខេមរា ។

# ប្រវត្តិ
# ហ្វ្រង់ស័រ



ឪពុកខ្ញុំ ជាអ្នកបច្ចេកទេស ខាងដាំកៅស៊ូ ។ ហ្វ្រង់ស័រនិទាន! គ្រួសារខ្ញុំ បងប្អូនជាច្រើននិងបារាំងផ្សេងទៀត



ចាកចេញ ពីកំពង់ផែ " ម៉ារស៊ី " ឆ្ពោះមកព្រៃនគរ នាឆ្នាំ ១៩៣៩ ។ ៣០ថ្ងៃ ទើបមកដល់ បើតាមយន្តហោះ ៥ថ្ងៃ តែប៉ុណ្ណោះ ។

ដើម្បីដាំត្រូវកាប់គាស់ព្រៃ ឆាយដី ។ ពីដើមស្រុកខ្មែរ ដើមឈើធំៗ ហើយ សម្ភារៈពុំសម្បូណ៌ទៀត ។ ណាមួយ ជម្ងឺគ្រុនចាញ់ និងជម្ងឺផ្សេងៗទៀត ពស់ចឹក ខ្លាស៊ី...បារាំងត្រូវការកម្លាំងមកជួយធ្វើការ ។

បារាំងទៅចាប់យួន ពីស្រុកយួន យកមកធ្វើការ នៅស្រុកខ្មែរ ។ ហេតុនេះហើយ បានជា មានយួន ជាច្រើន នៅស្រុកខ្មែរ ជាពិសេសយួនហ្វ ។ គេសំគាល់ពួកនេះ ដោយមានធ្មេញខ្មៅ ។

ឡុង សួរទៅ ហ្វ្រង់ស័រ ! គេចាប់មនុស្ស ដូចម្ដេចទៅ ចាប់ដូចប្រមាត់ប្រមង់ ហ្គងមួយៗ?

-មិនដូចនេះទេ ហ្វ្រង់ស័រឆ្លើយ ។

គេជ្រើសរើសថ្ងៃ យកថ្ងៃបុណ្យ ។ យករដូវណា ពេលដែលមនុស្សទំនេរច្រើន ជាពិសេស ក្រោយពីពេលច្រូតកាត់ហើយ ។

បារាំងយកកុប៉ាល់ធំ ទៅចតនៅជិតច្រាំងមួយ រួចបើកឲ្យមនុស្សម្នាឡើងលេងលើកុប៉ាល់ ។ ពេលយប់មានភ្លើងភ្លាត់ មានទឹកផឹក និងអំណោយផ្សេងទៀត ។

ដំណឹងនេះឮពីមាត់មួយទៅមួយ ពីដើមភូមិដល់ចុងភូមិ ។ យួនកាន់តែច្រើនឡើងៗ នាំគ្នាមកមើលល្ខោន ស្តាប់ភ្លេងលើកុប៉ាល់ ។

នៅថ្ងៃទីបី មនុស្សកាន់តែច្រើនឡើងទ្វេ ។ យួនភ្លឹកភ្លេចខ្លួន ជក់នឹងល្បែងកំសាន្តផ្សេងៗ ។ ពេលនោះបារាំងចាប់ស្រាយពួរ បណ្តែតកុប៉ាល់ ឲ្យទៅដល់កណ្តាលទន្លេ រួចបារាំងចាប់ដាក់ខ្នោះ មនុស្សណាមានកម្លាំង កំហែង អាចធ្វើការ កាប់គាស់ព្រៃបាន ។ មនុស្សចាស់ដែលពុំអាចធ្វើការបាន ត្រូវលើកបោះទម្លាក់ក្នុងទឹក យួនណាហ៊ានតដៃ ត្រូវគេសម្លាប់ចោល ។ យួនទាំងនេះត្រូវដឹក



យកមកស្រុកខ្មែរ ធ្វើការឲ្យបារាំង ។ នៅកន្លែងណា ត្រូវនៅកន្លែងនោះ យួនទាំងនេះ គ្មានសិទ្ធិ អំណាច នឹងដូរទីលំនៅឡើយ << ធ្វើការស៊ីដេក រួចស៊ីដេកធ្វើការ >> នេះជាជីវិតនៃគូលីចំការកៅស៊ូ ។

ដើមកៅស៊ូ ខ្លះឲ្យឈ្មោះថា << រុក្ខា ស្រក់ទឹកភ្នែក>> ព្រោះជ័រ ចេញពីដើមឈើ ស្រក់តក់ៗ ដូចទឹកភ្នែក ហូរព្រោះអាណិតដល់គូលី ។ ឯម្ចាស់ចំការ ប្រមូលលុយ រស់នៅ ដោយក្តីរីករាយ ។ ដល់វ័យសិក្សា ឪពុកយកទៅឲ្យរៀនសាលានៅឯព្រៃនគរ ។ ភ្នំពេញពុំទាន់មានសាលានៅឡើយ ។

ឱ! កម្ពុជាដ៏ល្អ សំរាប់គ្រួសារខ្ញុំ និងសំរាប់ខ្លួនខ្ញុំ ខ្ញុំពុំភ្លេចគុណអ្នកឡើយ ។ ខ្ញុំនឹងតបស្នងសងគុណអ្នក រាល់ឱកាសដែលខ្ញុំមាន ។

បារាំងផ្សេងទៀត ធៀតប្រើអំណាច គៀបសង្កត់ បង្អត់ម្ចាស់ស្រុក ធ្វើទុក្ខបុកម្នេញ ទាត់ធាក់វាយដំខ្មែរ ជាការកំសាន្ត ។

បារាំងរស់នៅដោយសាន្តត្រាណ រហូតដល់ឆ្នាំ១៩៣៩ ទើបមានការរំដើបបះបោរ ។

មតិបារាំង ជំនាន់នោះ ជឿជាក់ថា៖ គ្មានកំឡាំងណាអាចវាយប្រហារបារាំងបានឡើយ ។

បារាំងតែងបទ និងនាំគ្នាច្រៀង៖

" Ma‧ton ki ki...

តុងកឹង ក្រុងដ៏ល្អនៃខ្ញុំអើយ!

តែព្យុះសង្ឃរា នៅមិនឆ្ងាយឡើយ ។ ផ្ទុកបន្ទោរ សញ្ញាពិទិស ខាងកើតប្រាប់ថា ចលនាតស៊ូ ទាមទារឯករាជ្យ ចាប់បដិសន្ធិហើយ ។ ម្ចាស់ស្រុក ម្ចាស់ដី គេទាមទាររបស់របរគេវិញហើយ ។ បុកក្រអឹត ក្រទម របស់យើង ត្រូវគេកាច់បំបាក់វិញម្តងហើយ ។

ឆេទី នាងនិយាយម្តងពេលដែលប្រូខ់ស៊ះ ឈប់ ។ ខ្ញុំបានជួបគ្រួសារយួនម្នាក់និយាយថា គាត់ជាទាហានបារាំងពីដើមធ្លាប់ធ្វើសង្គ្រាមនៅ ឌៀនបៀនភូ ។



ប្រូខ់ស៊ះ និទាន ! ឌៀនបៀនភូ ជាគន្លុកវាលមួយដ៏ធំហ៊ុមព័ទ្ធជុំវិញដោយភ្នំ ។

បារាំងយល់ថា ទីនេះជាបន្ទាយដ៏ល្អ សំរាប់បារាំងហ៊ុមជុំវិញ ដោយភ្នំជាកំពែងការពារដ៏រឹងមាំ ។ តែការយល់នេះបែរជាខុសស្រឡះទៅវិញ ព្រោះយួនធ្វើពលិកម្មដ៏មហិមា ដឹកទាញអូសឡើងលើកំពូលភ្នំ កាណុងធំៗរួចបាញ់ផ្ទក់ចុះក្រោម ទៅលើបន្ទាយបារាំង ។ ឯកុប៉ាល់ហោះដែលបំរុងជួយ ក៏ត្រូវយួនបាញ់ពីលើភ្នំ ធ្វើឲ្យអាក់យាំងដំណើរ ។

ឌៀនបៀនភូ ទម្លាក់រារុជ បារាំងចុះចាញ់យួន ។ នៅឆ្នាំ១៩៥៤ ថ្ងៃ២០ ខែ៧ សន្និសីទទីក្រុងហ្សឺណែវ បែកទឹកដីវៀតណាម ជាពីរ ។

ឡុខ ឲ្យយោបល់ ! មិនមែនតែបារាំងទេ ដែលចង់គ្រប់គ្រងឥណ្ឌូចិន មានជប៉ុនទៀត ។ ប្រូខ់ស៊ះ មានដឹងខ្លះទេ ពេលដែលជប៉ុនចាប់បារាំងនៅឥណ្ឌូចិន គេថាក្នុងតែបីថ្ងៃ តែប៉ុណ្ណោះ បារាំងចុះចាញ់ ។

ម្រូចសំរ! ងក់ក្បាល ។

ខ្ញុំនឹងនិទានឲ្យអ្នកស្តាប់ ។ គឺចាប់ពីពេលនោះហើយ ដែលខ្ញុំចង មិត្តភាព ជាមួយ គ្រួសារ ខ្មែរម្នាក់ រហូតដល់ពេលឥឡូវ គឺគ្រួសារ ខេមរា នេះឯង ។

ជប៉ុនតាំងទ័ពជាជំបូងនៅ ហៃហុង ឡៅកាយ និងឡាំងសុង ក្រោមបញ្ជាការ ឧត្តមសេនីយម្នាក់ឈ្មោះនិស៊ីហារ៉ា( Ni shi hara ) នៅ ថ្ងៃ ៩/៤/៤៥ ពេល ល្ងាច ជប៉ុន ចាប់បារាំង ដកអាវុធ អស់ ក្នុងរយៈ តែ ២ ឬ ៣ ម៉ោង ប៉ុណ្ណោះ មិនមែនបីថ្ងៃនោះទេ ។

ឈុខនឹកក្នុងចិត្ត! នេះបានសមមុខបារាំង ក្រអឺតក្រទមតងអន្ទាក់ខ្លា ប៉ះចំគេខ្លាំងដែរ បាក់ធ្មុង ក្នុងរយៈបីម៉ោង ។ ខ្ញុំនៅចាំកាលណោះចាស់ៗនិទានថា ឃើញបារាំងដែលរត់រួចខ្លួន ពីជប៉ុនចាប់ សុំបាយជ្រូក ព្រោះឃ្លានពេក ។

ម្រូចសំរ បន្ត! ពេលនោះ គ្រួសារខ្ញុំ គេចផុតពី ជប៉ុន រត់ពួន នៅក្នុងព្រៃជិតខ្ទមមួយ មានជំណាំ បន្លែព័ទ្ធ ជុំវិញ ។ ម្ចាស់ផ្ទះគួរសមពន់ពេកក្រៃ ទទួលខ្លួនលាក់បំពួនគ្រួសារខ្ញុំ នៅក្នុងគុម្ពចេក ។ អ្នកដឹងហើយ ច្បាប់ជំនាន់នោះ បើឃើងលាក់បំពួនសត្រូវជប៉ុនមុខជាសម្លាប់ចោលមិនខាន ។

ម្ចាស់ផ្ទះជរាបន្តិច ហើយមានជម្ងឺទៀត រស់នៅជាមួយចៅប្រុសម្នាក់អាយុប្រហាណ៥ឆ្នាំ ។ ចៅនោះហើយជាអ្នកនាំចំណី អាហារ ផ្សេងៗ ចិញ្ចឹម គ្រួសារខ្ញុំ ។ កុមារនោះ គឺខេមរា នោះឯង ។

ឆេទីនាងសួរ! ចុះឪពុក បងខេមរា នៅឯណា?

ជន ចាស់ជរា ជាជីដូន មិនមែនម្តាយខេមរា នោះទេ ។ ម្តាយខេមរា ស្លាប់ តាំងពី ខេមរា ទើបនឹងកើត ម៉្លេះ ។ ឪពុកខេមរា ត្រូវបារាំង ចាប់ខ្លួន បំរុងនឹងបញ្ជូនទៅកោះត្រឡាច ព្រោះពួគគេចោទជាមេខ្មែរឥស្សរៈ នៅម្តុំខាងមេមត់ ។

ឈុខសួរ! ម្រូចសំរ អ្នករស់នៅ លាក់បំពួនខ្លួន ប៉ុន្មានថ្ងៃដែរ ។

ម្រូចសំរ ឆ្លើយ! ច្រើនខែដែរ ។ យើងខ្ញុំរង់ចាំ រហូតដល់ជប៉ុនចុះចាញ់ ដោយអាមេរិកម្នាក់ គ្រាប់បែកបរមាណូ

នៅលើក្រុង ហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី ថ្ងៃ៦ និងថ្ងៃ៩ ខែ៨ ឆ្នាំ១៩៤៥ ។

ជប៉ុនចុះចាញ់ នៅថ្ងៃ២/៩/៤៥។ ពេលនោះនៅស្រុកខ្មែរ មាននាយករដ្ឋមន្ត្រី សឺនង៉ុកថាញ់ ចូលដៃជាមួយជប៉ុន ។ ដល់ជប៉ុនចុះចាញ់ បារាំងចាប់សឺនង៉ុកថាញ់ ដាក់ពន្ធនាគារ ។

ឡុងបន្ត! រឿងនេះ ប្លែកណាស់ ឪពុក ខេមរា ត្រូវបារាំងចាប់ធ្វើបាប បំរុងនឹងបញ្ជូនទៅកោះត្រឡាច ឯជីដូនខេមរា យកខ្លួន ជួយយកអាសារបារាំង មិនខ្លាចស្លាប់។

ច្រូងសំបន្ត! ឲ្យតែបារាំងមិនមែន សុទ្ធតែអាក្រក់ទាំងអស់នោះទេ។ ឲ្យតែបារាំងមិនមែនជាអ្នកជិះជាន់ រឹបអូសយកសម្បត្តិទ្រព្យ ពីប្រទេសបំណុះនោះឡើយ។

ពូគង់ ឪពុក ខេមរា ជាអ្នកស្នេហាជាតិ ។ បំណងរបស់គាត់ គឺទាមទារឯករាជ្យ ។ ចំពោះខ្ញុំ ជាការទាមទារដ៏ត្រឹមត្រូវ តែចំពោះប្រយោជន៍ប្រទេសបារាំងវិញ បារាំងត្រូវចាត់ពូគង់ ជាសត្រូវនឹងប្រយោជន៍គេ គេត្រូវតែយកចេញឲ្យឆ្ងាយ ។ យ៉ាងណាមិញ ខ្មែរនិងខ្មែរ ក៏ពុំយល់ពុំ



ដូចគ្នាដែរ ខ្លះចូលដៃចូលជើង ជាមួយបារាំង ខ្លះច្បាំងប្រឆាំងនឹងបារាំង ។ ពូគង់ប្រហែលជា មានពេលខ្លះ ច្បាំងនឹងឪពុកខេមរីផង ក៏មិនដឹង? ឪពុកនិងឪពុកច្បាំងប្រហារគ្នា ឯកូនកំព្រាស្នេហាគ្នា សាងជីវិតថ្មី លើគំនរបាក់បែកនៃកម្ពុជាអភ័ព្វ ។



# ទាមទារឯករាជ្យ

ពេលនោះ មិនមែន មានតែ ប្រទេសខ្មែរ មួយទេ ដែលមានចលនា បះបោរ ទាមទារ ឯករាជ្យ ។ ប្រទេសនានា ផ្សេងទៀត ដែលនៅក្រោមអាណានិគម បារាំង អាហ្វ្រិក អារ៉ាប់ អាស៊ី ផុសផុល ទាមទារឯករាជ្យ ។

នៅស្រុកខ្មែរមាន ចលនាខ្មែរឥស្សរៈ កើតឡើងនៅឆ្នាំ១៩៤៧ ដោយលោក ស៊ើ ហេង ។ ឆ្នាំ១៩៥០ ចលនានេះ ដឹកនាំដោយ សឺនងុកមិញ ។ ក្រោយមកចលនានេះបែកជាពីរ មួយចូលជាមួយសៀម ដឹកនាំដោយ សឺនង៉ុកថាញ់ មានឈ្មោះថាខ្មែរសេរី ។ មួយទៀតចូលជាមួយយួន ដឹកនាំដោយ សឺនងុកមិញ ។



នៅក្នុងខេត្តកំពង់ចាម ផ្នែកខាងកើត ទន្លេមេគុង ខ្មែរឥស្សរៈ ដឹកនាំដោយពូ គង់ ឪពុកខេមរា ។

ពូគង់មានជំនួយម្នាក់ឈ្មោះ គន បែកគំនិត យកចលនាខ្មែរឥស្សរៈ ប្លន់យករបស់របរ ដែលខ្លួនរឹបបាន យកទៅលក់ យកលុយចែកបាយគ្នីគ្នា ។

ពូ គង់ និយាយថា៖ យើងមិនត្រូវធ្វើដូចនេះឡើយ ។ យើងមិនត្រូវលក់របស់ទាំងនេះយកលុយទេ ត្រូវតែចែករបស់នេះដល់អ្នកស្រុក អ្នកស្រែ ឲ្យសប្បាយចិត្ត ។ អ្នកស្រុកនឹងនាំគ្នាគាំទ្រ យើងទៅថ្ងៃក្រោយទៀត ។ ចលនាយើង ខ្មែរឥស្សរៈ ជាចលនា ស្នេហាជាតិ មិនមែនជាចោរប្លន់ ឥតមានមនសិការ នោះឡើយ ។ អ្វីដែលយើងចង់បាន គឺឲ្យបារាំង ចាកចេញ ពីទឹកដី យើងក្នុងពេលឆាប់ៗនេះ ។ ខ្ញុំគ្មានចេតនា នឹងសម្លាប់បារាំងសោះឡើយ ខ្ញុំពុំចង់មានកម្មពៀរ វេរានឹងគ្នា ប្រពាក់វាកវិន ដល់ជាតិក្រោយៗទៀត ។

តែគេពុំព្រមស្តាប់ យករបស់ដែលរឹបបាន ពីក្បួនរថយន្តបារាំង ដឹកស្បៀង ទៅលក់ ស៊ីបាយផឹកស្រា ។ អ្នកទាំងពីរ ចាប់មានការរកាំរកូស រវាងគ្នាបន្តិចម្តងៗ ។

ថ្ងៃមួយ គេនឹកក្បត់ លួចឲ្យពត៌មានដល់ទាហានបារាំងថា ពូ គង់ ប្រុងវាយ ស្ទាក់ឡាន ដឹកស្បៀងទាហាន នៅមុំប្រធាតុ ជិតកណ្តាលជ្រុំ ។

ពេលនោះ នាងស៊ីនួន ប្រពន្ធ ពូគង់ មានផ្ទៃពោះ ជិតគ្រប់ខែ ។ នាងទៅដងទឹក នៅក្នុងបឹង ។ ពេលព្រលឹមស្រាងៗ កាំរស្មីនៃព្រះអាទិត្យ ក្រហមឆ្អៅ ជះរស្មីចូលទៅក្នុងបឹងដូចឈាម ។

ស៊ីនួនយកដៃអង្អែលផ្ទៃរួចស្រដីថា៖

កូនមាសម្តាយ! ឪពុកនិងម្តាយកូនឯងតស៊ូ យូរអង្វែងគ្មានថ្ងៃណាសប្បាយរីករាយ បន្តិចឡើយ ។ រស់ដោយភិតភ័យ ដូចម្រឹគត្រូវព្រានទន្ទ្រានរានរក ឥតជំរក រងាតោកយ៉ាក ដេកមិនឆ្អែត ស៊ីពុំឆ្អាញ់ ព្រាត់បងប្អូន នេះព្រោះចង់បានសេរីភាព ចង់បានឯករាជ្យ ពីបារាំង នេះគឺសំរាប់



ផលឯង ផលខ្មែរទូទៅ តទៅថ្ងៃមុខ រស់នៅឲ្យបានរុងរឿង សម្បូណ៌សប្បាយ ។ ព្រោះយើងជាម្ចាស់នៃស្រុកយើង យើងនាំគ្នាកសាងស្រុក ទៅតាមលំនាំគំនិត ដែលយើងចង់បានទាំងអស់គ្នា ។

ម្តាយសង្ឃឹមថា អ្នកដឹកនាំប្រទេសទៅថ្ងៃក្រោយ មិនភ្លេចឡើយនូវញើសឈាមនៃអ្នកតស៊ូ ពេលនេះ ។

និយាយមិនទាន់ចប់ផង គ្រាប់កាំភ្លើងមួយគ្រាប់ រត់បាញ់ទម្លុះដើមទ្រូង ស៊ីនួនរមៀលធ្លាក់ក្នុងបឹង ។ ឈាមហូរចូលបឹងក្រហមឆ្អិនឆ្អៅ ។

ពូគង់រត់មក លើកបីត្រកងប្រពន្ធ ដៃស្តាំកាន់កាំភ្លើង ដៃឆ្វេងរែកសក់ មើលមុខប្រពន្ធ ដែលឈឺចាប់នឹងរបួសហួសពីការទ្រាំបាន ។ ទឹកភ្នែក ស៊ីនួន ហូរលាយជាមួយឈាម ។

ប្តីសម្លាញ់អូនអើយ! ថ្ងៃនេះជាអវសាន្តនៃជីវិតអូនហើយ ។ បង! មើលព្រះអាទិត្យបាច់រះ ព្រលឹងអូននឹងលា

ចាកទឹកដីខ្មែរ ទឹកដីជាតិស្រឡាញ់ ។ អ្នកមិនទាន់ស្គាល់នូវឯករាជ្យនៅឡើយទេ។ ផ្លូវនៅឆ្ងាយទៀត ។

ប្តីសម្លាញ់! ទុកអូនម្នាក់ឯងចុះ! បងរត់យកអាយុសិនទៅ! បន្តការតស៊ូទៀត សំរាប់អនាគតប្រទេសយើង!

ពេលនោះសម្តេចកូនង៉ា បាប់ស្រែកឡើង ។ តើសម្តេចខេមរា ដែលបានឃើញពន្លឺថ្ងៃ ។ ខេមរា ពុំបានឃើញឈាមម្តាយហូរចូលក្នុងបឹងទេ ហើយក៏ពុំបានឮសូរ សម្តេចបុកបាប់ម្តាយដែរ។

ពូគន់ លើកកូនដាក់ជិតដៃស៊ុនួន ។ នាងខំប្រឹងអង្អែលកូន រួចខំញញឹម ។

ឱកូនប្រុស ម្តាយជ្រើសរើសផ្លូវស្នេហាជាតិ ផ្លូវនៃអ្នកក្លាហាន ។ តែជីវិតជួបគ្រោះអាសន្ន មិនមែនជាផ្លូវ សម្បូសុខនោះឡើយ ។

ពេលនោះនាយឆនមកដល់ល្ហម មានទាំងទាហានបារាំងនៅពីក្រោយ ។

ពូគន់យល់ថា ឆនក្បត់គ្នាឯងហើយ ។



ពូគន់ យកដៃបិទភ្នែក ស៊ុនួនកុំឲ្យនាងឃើញ"មនុស្សអាក្រក់" តែស៊ុនួនបានចូលមរណភាពមុននេះបន្តិច ។

- "ក្រោកឡើង! ទម្លាក់អាវុធចុះ" ឆន ស្រែក គំរាម ពូគន់ ។

ពូគន់ដាក់កាំភ្លើងចុះ ដៃបីកូនខ្ចី ។

- អញសម្លាប់ឯងឲ្យអស់មួយពូជ ឆននិយាយ ! អញនឹងក្លាយទៅជាអ្នកមានបួយ អញលក់របស់ដែលបូន់ពីបារាំងបាន ។ នេះហើយជាផ្លូវដ៏ល្អ សំរាប់គ្រួសារអញ ។

ឆនបាញ់ពូគន់មួយគ្រាប់ដួលដេកជិតប្រពន្ធ ។

ទាហានបារាំងមកដល់ល្ហម ពេលដែលឆនភ្ជង់កាំភ្លើងបំរុងនឹងសម្លាប់កូនខ្ចីទៀត។ តែបារាំងរុញកាំភ្លើងឆាកចេញ ហើយរុញឆនទៅមុខទៀតដេញរាវរកពួកឥស្សរៈ។ ទារកនេះគឺខេមរា នោះឯង ។ នេះជាប្រវត្តិរបស់ខេមរា ។

ធេវីសួរ! បងខេមរា កំព្រាឥតមានឪពុកម្តាយ ពីត្រឹមពេលនោះមក? ម្តេចបានជួបជីដូន?

ហ្វ្រង់ស័រ៖ បន្ត! ពូ គង់ របួសត្រូវទាហានបារាំងចាប់បាន ។ ឯខេមរាត្រូវគេបោះបោល នៅក្នុងព្រៃ ម្នាក់ឯង នៅជិត សពម្ដាយ ។

ក្រោយមក ក្រោយពីដឹងថាទាហានបារាំងដកថយ វិញអស់ ពួកឥស្សរៈលបៗទៅរើសរកសព យកទៅកប់ ធ្វើបុណ្យ ។ ខេមរាត្រូវគេរើសយកទៅប្រគល់ឱ្យជីដូនខាង ឪពុក ឈ្មោះយាយ ផាន់ ចិញ្ចឹមបីបាច់ថែរក្សា ។

<< កូនអើយឥតម៉ែ ឥតមានគេថែ ដូចម៉ែផងខ្លួន >>

ខេមរា ខ្វះនូវការថ្នាក់ថ្នម ពីឪពុកម្ដាយ ខ្វះក្លិនម្ដាយ ដែលធ្វើឱ្យគេ ដល់ធំឡើងជាមនុស្ស ស្ងាត់ស្ងៀម រិះគិត ច្រើនពីរឿងជីវិត ។

ធេវី នាងសួរ បន្តទៀត! ចុះឪពុក បងខេមរា ទៅជា យ៉ាងណាទៅ?

ហ្វ្រង់ស័រ - ធេវីស្គាល់ពូគង់ទេ ពូម្នាក់បាក់ដៃ យាមសារមន្ទីរ និងឃ្លាំងឥវ៉ាន់ផ្សេងៗ ពូនេះហើយជាឪពុកខេមរា ។

ចា៎ះ! ខ្ញុំស្គាល់ គាត់គួរសមណាស់ ហើយឆ្លាតវៃទៀត ។ ខ្ញុំស្ដាយណាស់ ដោយពុំដឹងរឿងរ៉ាវទាំងនោះសោះ ម៉្លេះ



ខ្ញុំសាកសួរ ឱ្យបានច្បាស់ពីបំណង របស់គាត់ និងពីជីវិត តើគាត់យល់យ៉ាងណាដែរ បន្ទាប់ពីរឿងបែកបាក់គ្រួសារ រឿងមិត្តក្បត់មិត្ត ។ល។ រឿងស្រុកទេស ។ល។

ហ្វ្រង់ស័រ! ជាធម្មតា មនុស្សក្បត់ គេឥតយកជាគ្នាទេ ដូចពូគង ។

ឯរឿងពូ គង់ ឪពុកខេមរា មានលំនាំដូចតទៅ ។

ខ្ញុំនិងគ្រួសារខ្ញុំ(ហ្វ្រង់ស័រនិយាយ) បន្ទាប់ពីបានរស់រាន មានជីវិត ដោយសារ ជូនផាន់ ជួយលាក់បំបាំងមក ក៏កើត មានចិត្តស្រឡាញ់រាប់អាន ជូនផាន់ និងខេមរា ហើយសន្យា ថា នឹងជួយគ្រួសារនេះ ឱ្យចាកផុត ពីភាពក្រីក្រលំបាក តោកយ៉ាក ។ ពួកយើងខ្ញុំ បានសួរទៅជូន ផាន់ ថាជូនចង់ បានអ្វីក្នុងជាតិនេះ តើជូនមានបំណងប្រាថ្នាយ៉ាងណា ប្រាប់ យើងខ្ញុំមក ខ្ញុំនឹងលៃលក ធ្វើយ៉ាងណា ជួយជូន ឱ្យបាន ដូចប្រាថ្នា បើយើងខ្ញុំអាចជួយបាន ។

ជូនផាន់ពេលនោះចាប់មានជម្ងឺផង បានរ៉ាយរ៉ាប់រឿង ពូគង់ឱ្យយើងខ្ញុំស្ដាប់ ដោយក្រៀមក្រំ ក្នុងចិត្តបំផុត ។

ពេលដែលយើងខ្ញុំបានស្ដាប់ហើយ យើងខ្ញុំដឹងថា បំណងជូនផាន់ ទី១ គឺចង់រកអ្នកណា ជួយចិញ្ចឹម បីបាច់ថែរក្សា ខេមរា ឲ្យបានរៀនសូត្រ ទៅជាអ្នកចេះដឹងនឹងគេ ព្រោះគាត់ចាស់ហើយ ហើយមានជម្ងឺទៀត មិនអាចបីបាច់ថែរក្សាចៅ ឲ្យបានយូរអង្វែងឡើយ។ ហើយចាប់តាំងពីបារាំងចាប់ ពូគង់មក គ្មានអ្នកណា ហ៊ានរាប់អានគ្រួសារគាត់ឡើយ។ គាត់មើលទៅឃើញខ្មៅងងឹត ចំពោះវាសនា ខេមរា។

ទី២ គឺចង់ឲ្យគេជួយ កុំឲ្យបារាំង សម្លាប់ពូគង់ ឬបញ្ជូនទៅកោះត្រឡាច ។

បំណងជូនផាន់ មិនចោទជាបញ្ហាដល់គ្រួសារខ្ញុំឡើយ។ គឺជាបំណងធម្មតានៃជនជាតិខ្មែរ ដែលចង់រស់នៅដូចគេដូចឯង មិនលោភលុយ លោភអំណាច។ល។ នៅប្រទេសបារាំង បំណងទាំងនេះជាសិទ្ធិនៃពលរដ្ឋ ដែលរដ្ឋត្រូវតែផ្ដល់ឲ្យចេះមើល ចេះអាន ចេះសរសេរអក្សរ ។



ជូនផាន់និងខេមរា ត្រូវគ្រួសារខ្ញុំយកមកឲ្យរស់នៅឯក្រុងភ្នំពេញ ឲ្យរៀនសូត្រ ដូចគេឯង។ ឯជូនផាន់ មានពេទ្យមកជួយមើលជម្ងឺ គាត់បានធូរស្បើយ ។ គាត់រមែងទៅមើលកូនគាត់ ពូគង់នៅក្នុងពន្ធនាគារ "គុកធំ" នាក្រុងភ្នំពេញ។

កុំតែបានជូនផាន់ជួយ ខ្ញុំម៉ុះស្លាប់បាត់ទៅហើយ ទាំងមា មីង បងប្អូនផ្សេងៗទៀត។

បារាំងឯទៀត នៅជិតៗទីនោះត្រូវជប៉ុន ចាប់យកទៅទាំងអស់។

យាយផាន់ ពេលនោះនៅមានអំណាច ព្រោះជាម្ដាយពូគង់មេឥស្សរៈ។ គេហៅយាយផាន់ថាជា "មាតាស្នេហាជាតិ"។ គ្មានអ្នកណាហ៊ានមកបៀតបៀនគាត់ឡើយ។ មេឥស្សរៈជំនាន់នោះ មិនមែនមិនដឹង ពីវត្តមាននៃយើងខ្ញុំនោះឡើយ តែគេទាំងនោះស្ដាប់បង្គាប់ យាយផាន់ ព្រោះគាត់បានប្រាប់ទៅមេឥស្សរៈថា "កូនប្រុសខ្ញុំតែមួយត្រូវបារាំងចាប់យកទៅ ចាប់ដោយសារបារាំងជាសត្រូវនឹងយើង ។